ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គិសនីកម្ពុជា**

លេខ : ៤០៧៤១ អសក.គត.ដកស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០១៣

# សេចក្តីជូនដំណឹង

**អគ្គិសនីកម្ពុជា** មានកិត្តិយសសូមជម្រាបជូនសេវាករអគ្គិសនីដែលកំពុង និងគ្រោងផ្តល់សេវាកម្មអគ្គិសនីនៅតំបន់ជនបទឲ្យបានជ្រាបថា៖ នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.) នៃអគ្គិសនីកម្ពុជាបានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជាឲ្យអនុវត្តន៍ "កម្មវិធីជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅជនបទ" ក្នុងគោលបំណងជួយសម្រួលឲ្យសេវាករអគ្គិសនីអាចមានទុនវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យម និងទាបនៅតំបន់ជនបទឲ្យពេញតំបន់ដែលអាជ្ញាធរអគ្គិសនីកម្ពុជាអនុញ្ញាត ដោយអគ្គិសនីកម្ពុជាតាមរយៈ ម.អ.ជ. ជាអ្នកជួយផ្តល់ថវិកាកម្ចីដោយគ្មានការប្រាក់ (សម្រាប់តំបន់២) និងផ្តល់ជាប្រាក់ឧបត្ថម្ភធនមួយផ្នែកបន្ថែមពីលើប្រាក់កម្ចីគ្មានការប្រាក់ (សម្រាប់តំបន់៣) និងអនុញ្ញាតឲ្យសេវាករបង់សងរំលស់មក ម.អ.ជ. វិញបន្តិចម្តងៗ ក្នុងរយៈកំណត់មួយ។ របៀបនៃការជួយ គឺសេវាករជាអ្នកសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីដោយខ្លួនឯង ប៉ុន្តែ ម.អ.ជ. ត្រួតពិនិត្យផែនការសាងសង់ និងតម្លៃហេដ្ឋារចនាសម្ព័ន្ធ រួច ម.អ.ជ. ទូទាត់ទុនឲ្យសេវាករទៅតាមភាពរីកចំរើននៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនេះ រហូតដល់ហេដ្ឋារចនាសម្ព័ន្ធបានសាងសង់រួចជាស្ថាពរ។ មុនពេលដែលសេវាករបង់រំលស់ទុនសងមក ម.អ.ជ. វិញ មិនទាន់គ្រប់ចំនួនដែលបានខ្ចី ហេដ្ឋារចនាសម្ព័ន្ធទាំងនេះ ជាកម្មសិទ្ធិរបស់ ម.អ.ជ.។ កម្មវិធីនេះនឹងចាប់ផ្តើមអនុវត្តន៍ក្នុងឆ្នាំ២០១៣ និងទៅតាមទំហំថវិកាដែល ម.អ.ជ. មាន។ លក្ខណៈវិនិច្ឆ័យសម្រាប់អនុវត្តន៍កម្មវិធីនេះ មានភ្ជាប់មកជាមួយ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកលោក សាន វីយ៉ាន ទូរស័ព្ទលេខ 012 854-809 លោក គឹម ឬទ្ធី ទូរស័ព្ទលេខ 089 267-071 ឬទាក់ទងផ្ទាល់មក ម.អ.ជ. តាមទូរស័ព្ទលេខ 023 997-600 ឬទូរសារលេខ 023 997-601 ឬអញ្ជើញមកទំនាក់ទំនងផ្ទាល់នៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខ័ណ្ឌឫស្សីកែវ ភ្នំពេញ។

អាស្រ័យហេតុនេះ សូមសេវាករអគ្គិសនីមេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយបន្តស្តីពីកម្មវិធីនេះចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។

ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
អគ្គនាយកស្តីទី

ចាន់_សុជាវ៉ាត

**ចម្លងជូន**

- អាជ្ញាធរអគ្គិសនីកម្ពុជា
- អគ្គនាយករងអគ្គិសនីកម្ពុជា
  ដើម្បី "ជូនជ្រាបជាព័ត៌មាន"
- ឯកសារ-កាលប្បវត្តិ